# នំដំឡូងដុត



អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

Written by Hen_Choven
Illustrated by Hen Choven



ថ្ងៃនេះ ដារីសប្បាយចិត្តណាស់ ដោយសារតែសត្វឆ្កែរបស់នាងបានចាក់ថ្នាំបង្ការជំងឺរួច។
នាងអាចលេងជាមួយវាដោយមិនបារម្ភទៀតឡើយ។



មួយសន្ទុះក្រោយមក ស្រាប់តែដារីធុំក្លិនឈ្ងុយអ្វីម៉្យាង។
«អូយ! ឈ្ងុយណាស់។ តើជាក្លិនអ្វី?»



«អូ! ប្រហែលជាម៉ាក់កំពុងធ្វើអ្វីហើយមើលទៅ»។ ដាវីបានតាមក្លិនឈ្ងុយនោះរហូតដល់ផ្ទះបាយ តែមិនឃើញអ្វីទាំងអស់។



«តើក្លិនឈ្ងុយនោះចេញពីសួនផ្កាមែនទេ?» «ចេញពីខាងក្រោមគ្រែឬ? អូ! មិនមែនទេ»។
«មើលទៅនៅខាងក្នុងទូដាក់ខោអាវទេដឹង? អូ! មិនមែនទេ»។ ដាវីក៏បន្តតាមក្លិនឈ្ងុយនោះទៀត។



«អាហ៎ា! ខ្ញុំរកឃើញហើយ»។

«តាមពិតក្លិនឈ្ងុយចេញពីផ្ទះលោកយាយទេតើ!»



ដារីសួរ «លោកយាយកំពុងធ្វើអ្វីហ្នឹង? វាពិតជាឈ្ងុយខ្លាំងណាស់»។

លោកយាយឆ្លើយ «យាយកំពុងដុតនំណ៉ាចៅ។ មកចៅ! នំឆ្អិនហើយ អាចញ៉ាំបាន»។



មិនបង្អង់យូរ ដារីបានចាប់នំដាក់ក្នុងចានជាច្រើនដុំ។ នាងពេញចិត្តនឹងការញុំានំនេះខ្លាំងណាស់។



ដារីសួរ «តើនំនេះគេហៅនំអ្វីទៅលោកយាយ?»

លោកយាយឆ្លើយ «នំដិឡូងដុត ឬអាចហៅឈ្មោះផ្សេងទៀតទៅតាមតំបន់នីមួយៗ»។ «វាជានំរបស់ខ្មែរយើង»។










ដារីបន្តសួរ «តើគ្រឿងផ្សំរបស់វាមានអ្វីខ្លះ? ហើយចម្អិនវាដោយរបៀបណា?» លោកយាយឆ្លើយ «ចាសចៅ គ្រឿងផ្សំមិនពិបាករកទេ»។ «មានដូចជា៖ ដំឡូងឈើ ឬគេអាចហៅថាដំឡូងគរ ទឹកដោះគោខាប់ ខ្ទិះដូងនិងពងមាន់ជាដើម»។



«របៀបធ្វើ ដាដិបូងយាយយកដំឡូងមកបកសម្បកចេញនិងសម្អាតវាឱ្យបានស្អាត។ បន្ទាប់មកទៀត យាយយកដំឡូងទៅឈូសជាសសៃល្អិតៗ។បានសាច់ដំឡូងហើយ យកវាមកច្របល់ជាមួយពងមាន់ ទឹកដោះគោខាប់ ខ្ទិះដូង ឱ្យចូលគ្នាបានល្អ។



រួចហើយ យកវាទៅដាក់ចំហុយ ឬកូរវាលើខ្ទះជាមុនសិនក៏បាន ដើម្បីឱ្យសាច់ដំឡូងស្អិតល្អតល្អ»។



«បន្ទាប់ពីចំហុយរួច យាយយកពងមាន់ផ្នែកក្រហមមកលាបពីលើនំបន្ថែមទៀត។
ចុងក្រោយ យាយយកវាទៅដាក់ដុត ដើម្បីឱ្យនំកាន់តែឈ្ងុយ ជាការស្រេចណាចៅ!»។



«វ៉ាវ! លោកយាយពិតជាពូកែណាស់។ អរគុណលោកយាយ ដែលឱ្យចៅបានស្គាល់នំខ្មែររបស់យើង»។

«តើចៅអាចយកនំខ្លះផ្ញើប៉ាម៉ាក់នៅផ្ទះបានទេ?» ដាវីសួរលោកយាយ។

«បានតើចៅ។ តស់! ចាំយាយជូនចៅទៅផ្ទះវិញ!»។ លោកយាយនិយាយទាំងញញឹម។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែល មិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូច ក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យ ចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើ សាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប ទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉ន លោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធាន បង្រៀន៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការTukTuk និងអង្គការ រ៉ូតារីក្លឹប។

ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការ(R4C) ដែលបានបង្កើតនិងចូលរួមកែសម្រួលសៀវភៅរឿងនេះឡើង ដោយក្តីមេត្តាធម៌។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន